# Year 1 Phonics Screening Check

Information for parents and carers

# ការត្រួតពិនិត្យសូរសព្ទ ថ្នាក់ទី 1

ព័ត៌មានសម្រាប់ឪពុកម្តាយ និងអ្នកថែទាំ




## តើសូរសព្ទគឺជាអ្វី?

សូរសព្ទគឺជាទំនាក់ទំនងរវាងអក្សរ និងសំឡេង ហើយមានសារៈសំខាន់ក្នុងការរៀនអាន។ កុមារខ្លះមានការលំបាកក្នុងការរៀនអាន ដូច្នេះវាជាការសំខាន់ដែលកុមារទាំងនេះត្រូវបានកំណត់អត្តសញ្ញាណយ៉ាងឆាប់រហ័ស។ តាមវិធីនេះ គ្រូអាចរៀបចំផែនការសម្រាប់ការគាំទ្រជាក់លាក់ណាមួយដែលកុមារប្រហែលជាត្រូវការ។

## តើការត្រួតពិនិត្យសូរសព្ទថ្នាក់ទី 1 ជាអ្វី?

ការត្រួតពិនិត្យសូរសព្ទថ្នាក់ទី 1 គឺជាការវាយតម្លៃទូទាំងរដ្ឋដ៏ខ្លីមួយដែលប្រាប់គ្រូពីរបៀបដែលកូនរបស់អ្នកកំពុងរីកចម្រើនផ្នែកសូរសព្ទ។ ការត្រួតពិនិត្យនេះសង្កេតមើលពីរបៀបដែលកូនរបស់អ្នកអាចអានពាក្យអង់គ្លេស ជាមួយនឹងអក្សរផ្គួបបញ្ចូលផ្សេងៗគ្នា។ កូនរបស់អ្នកនឹងអង្គុយជាមួយគ្រូ ហើយនឹងត្រូវបានស្នើសុំឱ្យអាន 40 ពាក្យយ៉ាងឮ។ ពាក្យទាំងនេះរួមមានពាក្យពិតចំនួន 20 និងពាក្យដែលគ្មានន័យចំនួន 20។ គោលបំណងនៃពាក្យដែលគ្មានន័យគឺដើម្បីមើល ថាតើសិស្សអាចប្រើចំណេះដឹងរបស់ពួកគេក្នុងការលាយចូលគ្នាដើម្បីអានពាក្យមួយ ជាជាងការចងចាំរបស់ពួកគេពីការបានឃើញពាក្យនោះពីមុនមក។ ការធ្វើតេស្តនេះជាធម្មតាចំណាយពេល 5-7 នាទី។ ប្រសិនបើកូនរបស់អ្នកមានការលំបាក គ្រូនឹងបញ្ឈប់ការត្រួតពិនិត្យ។ ការត្រួតពិនិត្យត្រូវបានរចនាឡើងដោយប្រុងប្រយ័ត្ន ដើម្បីកុំឱ្យមានភាពតានតឹងសម្រាប់កូនរបស់អ្នក។

គោលបំណងចម្បងនៃការត្រួតពិនិត្យសូរសព្ទថ្នាក់ទី 1 គឺដើម្បីផ្តល់ព័ត៌មានដល់គ្រូរបស់កូនអ្នក ដែលនឹងអនុញ្ញាតឱ្យពួកគេរៀបចំផែនការសម្រាប់ការរៀនសូត្ររបស់កូនអ្នក។ កុមារម្នាក់ៗត្រូវបានវាយតម្លៃជាលក្ខណៈបុគ្គលដោយគ្រូ ហើយសិស្សថ្នាក់ទី 1 ទាំងអស់នឹងត្រូវបានវាយតម្លៃ។

## ហេតុអ្វីបានជាសូរសព្ទមានសារៈសំខាន់?

ចំណេះដឹង និងជំនាញសូរសព្ទគឺចាំបាច់សម្រាប់ការរៀនអាន និងសរសេរជាភាសាអង់គ្លេស។ ដើម្បីទទួលបានជោគជ័យ សិស្សត្រូវការរៀនសំឡេងនានាដែលតំណាងដោយអក្សរនីមួយៗ ឬអក្សរផ្គួបបញ្ចូលផ្សេងៗគ្នា និងជំនាញនៃការលាយសំឡេងទាំងនេះចូលគ្នា ដើម្បីអានពាក្យនានា។ អ្នកអានដំបូងត្រូវការរៀនពីរបៀបលាយសំឡេងចូលគ្នាជាមួយពាក្យឱ្យបានរហ័ស និងដោយស្ទាត់ជំនាញ ដើម្បីកុំឱ្យរំខានដល់លំហូរនៃការអាន និងការដឹងយល់នៃអត្ថបទ។

សូមទាក់ទងមកសាលារៀន ប្រសិនបើអ្នកមានចម្ងល់ទាក់ទិននឹងការត្រួតពិនិត្យសូរសព្ទថ្នាក់ទី 1។

## សេវាកម្មអ្នកបកប្រែផ្ទាល់មាត់តាមទូរសព្ទ

ប្រសិនបើអ្នកត្រូវការជំនួយអ្នកបកប្រែផ្ទាល់មាត់ដើម្បីទាក់ទងមកសាលារៀន សូមហៅទូរសព្ទលេខ 131 450 ប្រាប់ការីទូរសព្ទនូវភាសាដែលអ្នកត្រូវការ ហើយស្នើសុំឱ្យពួកគេទូរសព្ទទៅសាលារៀន។ ការីទូរសព្ទនឹងរៀបចំអ្នកបកប្រែផ្ទាល់មាត់តាមទូរសព្ទ ដើម្បីជួយក្នុងការសន្ទនារបស់អ្នក។ គេនឹងមិនគិតថ្លៃសេវានេះពីអ្នកទេ។